**Declassified to Public**
**07 September 2018**

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២/០៧-០៩-២០០៩-អវតក/កសចស(អបជ....) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 23-Aug-2018, 12:17
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ:** **សម្ងាត់/Confidential**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមពេលវេលាកំណត់សម្រាប់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

**សហមេធាវី អោ អាន**
លោក មុំ លុជ្ជ
លោក Goran SLUITER
លោក Richard ROGERS

**ដើមបណ្ដឹងរដ្ឋប្បវេណី**
**ក្នុងសំណុំរឿង០០៤/២ ទាំងអស់**

១. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ ចំនួនពីរ ត្រូវបានចេញ៖ ដីកាដំណោះស្រាយមួយ គឺជាដីកាលើកលែងចោទប្រកាន់ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតជាតិ[1] និងដីកាដំណោះស្រាយមួយទៀត គឺជាដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[2]។ ដីកាលើកលែងចោទប្រកាន់បានចេញជាភាសាខ្មែរ ដោយគ្មានសំណៅបកប្រែជាភាសាអង់គ្លេសទេ ខណៈដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ មានតែភាសាអង់គ្លេស តែគ្មានសំណៅបកប្រែជាភាសាខ្មែរ។

២. សហព្រះរាជអាជ្ញាស្នើសុំការបញ្ជាក់បំភ្លឺថាតើ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយមួយ ឬទាំងពីរ នឹងត្រូវចាប់ផ្តើមគិតពេលណា ដោយសារយើងមានដីកាដំណោះស្រាយរហូតដល់ទៅពីរសម្រាប់សំណុំរឿងតែមួយ។ សហព្រះរាជអាជ្ញាទាំងពីររូបជឿថា ដើម្បីអាចធ្វើការសម្រេចចិត្តឲ្យបានគ្រប់ជ្រុងជ្រោយក្នុងបណ្តឹងឧទ្ធរណ៍ណាមួយ សហព្រះរាជអាជ្ញាត្រូវការត្រួតពិនិត្យលើឯកសារទាំងពីរ តាមរយៈភាសាដែលខ្លួនអាចយល់បានពេញលេញ។ លើសពីនេះដោយហេតុថា ដីកាដំណោះស្រាយទាំងពីរវែង (មានរហូតដល់ជាង ៤០០ទំព័រ សម្រាប់ដីកាដំណោះស្រាយនីមួយៗ) សហព្រះរាជអាជ្ញាត្រូវការពេលវេលាខ្លះ ដើម្បីវាយតម្លៃលើដីកាដំណោះស្រាយផង និងអំពីភាពប្រទាក់ក្រឡាគ្នាដ៏ស្មុគស្មាញនៃបណ្តឹងឧទ្ធរណ៍ផង។

៣. ទន្ទឹមនេះ សហព្រះរាជអាជ្ញា ស្នើសុំពន្យារពេលវេលាកំណត់ ដែលនឹងអនុវត្តចំពោះភាគីទាំងអស់ សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដីកាដំណោះស្រាយណាមួយ រហូតដល់ ១៤ថ្ងៃ បន្ទាប់ពីសំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរត្រូវបានជូនដំណឹង។

៤. អភិក្រមនេះនឹងទទួលបានផលប្រយោជន៍បន្ថែមពីភាគីទាំងអស់ តាមការផ្តល់ឲ្យពួកគាត់នូវនីតិវិធីស្មើៗគ្នា ដោយសារថា សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយណាមួយនៃដីកាដំណោះស្រាយទាំងពីរ នឹងចូលមកដល់ក្នុងពេលតែមួយ។ សហព្រះរាជអាជ្ញាសន្និដ្ឋាន

[1] ឯកសារ **D359** ដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន, ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨។

[2] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ), ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨។

ថា ប្រវែងដ៏វែងនៃដីកាដំណោះស្រាយ និងភាពពាក់ព័ន្ធគ្នាទៅវិញទៅមក គឺជាកាលៈទេសៈពិសេស ដែលជាយុត្តិកម្មសម្រាប់ការពន្យារពេលនេះ[3]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[3] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៨, ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ (“សេចក្តីណែនាំអនុវត្ត”), មាត្រា ៨.២។